វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

អនុក្រឹត្យលេខ/៨៨អនក្រ.បក/២៩ធ្នូ១៩៩៧

# អនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្រ្តីទី១ និង នាយករដ្ឋមន្រ្តីទី២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្រ្តីដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រមលេខ ០៣ ន.ស ៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីច្បាប់វិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា
- តាមការស្នើនៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា និងបានការឯកភាពពីគណៈរដ្ឋមន្រ្តី នាសម័យប្រជុំពេញអង្គថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ១៩៩៧

## សំរេច

## ជំពូក ១ បទបញ្ញត្តិទូទៅ

### មាត្រា១: និយមន័យ

១.១- អត្ថន័យនៃពាក្យបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

"អ្នកដាក់ពាក្យសុំ" មានន័យថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលឆ្លើយតបទៅនឹងលក្ខណសម្បត្តិ ដែលមានចែងក្នុងមាត្រា ៦.១.ច និងដែលបានដាក់ពាក្យសុំវិនិយោគ ឬសុំបង្កើតសហគ្រាសវិនិយោគ។ អ្នកដាក់ពាក្យសុំ នឹងអាចរាប់បញ្ចូលទាំងសហគ្រាស ដែលមានស្រាប់ដូចមានចែងក្នុងមាត្រា ៣.៤ និង មាត្រា ៥.២។

"ពាក្យសុំ" មានន័យថា សំណើសុំសេចក្តីអនុញ្ញាត ដើម្បីបានទទួលការលើកទឹកចិត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៣ ន.ស ៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ហើយត្រូវមានយ៉ាងហោចណាស់នូវឯកសារដែលមានចែងក្នុងមាត្រា ៦.១។

"អ្នកវិនិយោគ" មានន័យថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលឆ្លើយតបទៅនឹងលក្ខណៈសម្បត្តិដែលមានចែងក្នុងមាត្រា ៦.១.ច និង មាត្រា ៩ ហើយដែលបានធ្វើវិនិយោគរួចហើយ ឬធ្វើសំណើវិនិយោគ។

"សហគ្រាសវិនិយោគ" មានន័យថា នីតិបុគ្គលសញ្ជាតិខ្មែរ ឬនីតិបុគ្គលសញ្ជាតិបរទេស ដែលត្រូវបាន អនុញ្ញាតអោយវិនិយោគដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជា ណាចក្រកម្ពុជា និងអនុក្រឹត្យនេះ។

"នីតិបុគ្គលសញ្ជាតិខ្មែរ" មានន័យថា នីតិបុគ្គលដែលបានបង្កើតឡើង និង ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលមានរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរកាន់កាប់ច្រើនជាង ៥១% (ហាសិបមួយភាគរយ) នៃដើមទុនសរុប។

"នីតិបុគ្គលសញ្ជាតិបរទេស" មានន័យថា នីតិបុគ្គលដែលមិនមែនសញ្ជាតិខ្មែរ ហើយមិនបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

"ការលើកទឹកចិត្ត" មានន័យថា ជាបុព្វសិទ្ធិពិសេសមួយក្នុងបណ្តាបុព្វសិទ្ធិទាំងឡាយ ដែលរាជរដ្ឋាភិបាលផ្តល់ទៅអ្នកវិនិយោគស្របតាមលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានផ្សេងៗទៀត។

"វិនិយោគ" មានន័យថា គ្រប់គំរោងវិនិយោគទាំងឡាយដែលបានទទួលការលើកទឹកចិត្តណាមួយពីរាជរដ្ឋាភិបាលស្របតាមច្បាប់ និងបទដ្ឋានទាំងឡាយស្តីពីវិនិយោគ។

"ឧបសម្ព័ន្ធ" មានន័យថា ឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងជាផ្នែកមួយនៃអនុក្រឹត្យនេះ។

"ទំនិញជាទុន" មានន័យថា ជាទ្រព្យសកម្មរូបីយ៍ ដែលមានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំ (០១ឆ្នាំ)។

"ច្រកចេញ-ចូលតែមួយ" គឺសំដៅលើគណៈកម្មាធិការវិនិយោគកម្ពុជា ដែលជាយន្តការមួយ មានតួនាទីធ្វើការពិនិត្យ ពិភាក្សា ផ្តល់យោបល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យសំរេចលើគម្រោង វិនិយោគឯកជន។

## មាត្រា២: ការដាក់អោយអនុវត្ត និងគោលដៅនៃអនុក្រឹត្យនេះ

២.១- ការដាក់អោយអនុវត្ត : អនុក្រឹត្យនេះ ត្រូវដាក់អោយអនុវត្តចំពោះរាល់ការវិនិយោគ សកម្មភាពវិនិយោគ និងសហគ្រាសវិនិយោគទាំងឡាយណាដែលបានទទួលការអនុញ្ញាត និងការលើកទឹកចិត្តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

២.២- គោលដៅ: អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការអនុវត្តន៍ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងមានគោលដៅលើកទឹកចិត្ត ព្រមទាំងមានគោលដៅគ្រប់គ្រងសម្រប សម្រួលរាល់សកម្មភាព និងការងារវិនិយោគដោយអ្នកវិនិយោគសញ្ជាតិខ្មែរ និងបរទេសក្នុងព្រះ រាជាណាចក្រកម្ពុជា។

## មាត្រា៣: វិស័យសំរាប់វិនិយោគ

៣.១- វិស័យវិនិយោគ: បញ្ជីវិស័យវិនិយោគដែលត្រូវបានទទួលការលើកទឹកចិត្ត ឬគ្មានការលើកទឹកចិត្ត គឺមានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ។ ឧបសម្ព័ន្ធនេះ នឹងអាចត្រូវបានធ្វើ វិសោធនកម្មជាបន្តបន្ទាប់។

៣.២- ការដាក់កំហិតលើវិស័យមួយចំនួន : ការដាក់កំហិតលើវិស័យមួយចំនួនសំរាប់វិនិយោគ ត្រូវកំណត់ដោយអនុក្រឹត្យ ដោយផ្អែកលើមូលដ្ឋាននៃសន្តិសុខជាតិ សុវត្ថិភាពសង្គម ឬភាពចាំបាច់នៃសេដ្ឋកិច្ចជាតិ។

៣.៣- វិស័យហាមឃាត់វិនិយោគ: គ្រប់សកម្មភាពវិនិយោគដែលផ្ទុយពីបទបញ្ញត្តិនៃច្បាប់ទាំងឡាយជាធរមាន ត្រូវបានហាមឃាត់។

៣.៤- សហគ្រាសវិនិយោគដែលមានស្រាប់ : ចំពោះសហគ្រាសវិនិយោគដែលមានស្រាប់ ក្នុងករណីដែលមានការដាក់កំហិតលើវិស័យមួយចំនួនដូចមានចែងក្នុងមាត្រា ៣.២ ខាងលើនេះ រាជរដ្ឋាភិបាល មានកាតព្វកិច្ចបង្កើតគណៈកម្មការចំរុះមួយដែលមានសមាសភាពរាជរដ្ឋាភិបាល និងអ្នកវិនិយោគដើម្បីដោះស្រាយបញ្ហានេះ តាមភាពសមរម្យដោយមានការឯកភាព

ទាំងសង្ខាង ដូចជាភាគីម្ខាងៗ ត្រូវតែងតាំងអ្នកប៉ាន់តំលៃមួយនាក់ ហើយតំលៃដ៏សមរម្យនោះ គឺជាតំលៃមធ្យមភាគនៃតំលៃ ដែលបានកំណត់ដោយអ្នកប៉ាន់តំលៃទាំងពីរនាក់នោះ។ ក្នុងករណីដែលភាពខុសគ្នារវាងតំលៃប៉ាន់ស្មានទាំងពីរនោះច្រើនជាង ១៥% (ដប់ប្រាំភាគរយ) នៃតំលៃប៉ាន់ស្មានដែលធំជាងគេ អ្នកប៉ាន់តំលៃឯករាជ្យម្នាក់ទៀត ត្រូវបានតែងតាំងដោយអ្នកប៉ាន់តំលៃឯករាជ្យទាំងពីរនាក់មុន ដើម្បីកំណត់យកតំលៃដ៏សមរម្យ នៅក្នុងចន្លោះរវាងតំលៃប៉ាន់ស្មានទាំងពីរនោះ។ អ្នកវិនិយោគ ត្រូវទទួលប្រតិបត្តិតាមតំលៃចុងក្រោយនេះ ដោយគ្មានការតវ៉ា។

មាត្រា៤: អ្នកវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

៤.១- វិនិយោគនៃបរទេស: រាជរដ្ឋាភិបាលស្វាគមន៍ជានិច្ចដល់រាល់វិនិយោគពីសំណាក់ជនបរទេស លើគ្រប់វិស័យសេដ្ឋកិច្ច ដោយលើកលែងតែសកម្មភាពមួយចំនួនស្ថិតនៅក្រោមការហាមប្រាមនៃបញ្ញត្តិ ច្បាប់ លិខិតបទដ្ឋាន ប្រកាស ឬ អនុក្រឹត្យ។

៤.២- ការប្រើប្រាស់អ្នកឈរឈ្មោះ: គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដែលមានសញ្ជាតិខ្មែរអាចធ្វើការជំនួស ឬតំណាងផ្ទាល់ ឬដោយប្រយោលអោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិបរទេស ក្នុងគោលបំណងដើម្បីជៀសវាងនូវការអនុវត្តនៃអនុក្រឹត្យនេះ និងដើម្បីបង្កលក្ខណៈងាយស្រួលអោយ ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិបរទេស ឬជនបរទេសក្នុងបំណងជៀសវាងនូវឥទ្ធិពលនៃ ការដាក់កំហិត ឬការហាមឃាត់ណាមួយដល់សកម្មភាពរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិបរទេស ឬជនបរទេសនោះបានឡើយ។

## ជំពូក ២ ការដាក់ពាក្យសុំ និងការអនុញ្ញាតវិនិយោគ

មាត្រា៥: ការដាក់ពាក្យសុំវិនិយោគ

៥.១- ការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា: ដោយអនុលោមទៅតាម មាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២ នៃអនុក្រឹត្យនេះ អ្នកវិនិយោគដែលចង់បានទទួលការលើកទឹកចិត្ត ត្រូវមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៥.២- សហគ្រាសវិនិយោគដែលមានស្រាប់: សហគ្រាសវិនិយោគដែលបានបង្កើតឡើងរួចមកហើយ មុនកាលបរិច្ឆេទនៃប្រសិទ្ធភាពមានអនុក្រឹត្យនេះដោយពុំគិតថា តើសហគ្រាសវិនិយោគនោះ បានចាប់ផ្តើមក្តី ឬពុំទាន់ចាប់ផ្តើមក្តី នូវប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលប្រាថ្នាចង់បានការលើកទឹកចិត្តវិនិយោគ ត្រូវតែរៀបចំបែបបទដាក់ពាក្យសុំ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ការដាក់ពាក្យសុំវិនិយោគក្នុងករណីនេះ គឺគ្រាន់តែជាបែបបទបន្ថែម សំរាប់ការលើកទឹកចិត្តតែប៉ុណ្ណោះ។

៥.៣- ពាក្យសុំ : ពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ត្រូវចុះហត្ថលេខា និងដាក់ដោយអ្នកដាក់ពាក្យសុំ ឬដោយតំណាងពេញសិទ្ធិម្នាក់របស់អ្នកដាក់ពាក្យសុំ ហើយត្រូវដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច។ លិខិតប្រគល់សិទ្ធិ ត្រូវជាលិខិតដែលមានសុពលភាព ហើយត្រូវភ្ជាប់ជាមួយពាក្យសុំនេះ។

មាត្រា៦: ល័ក្ខខ័ណ្ឌតម្រូវសំរាប់ដាក់ពាក្យសុំ

៦.១- ឯកសារសំរាប់ដាក់ពាក្យសុំ : ពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ត្រូវមានឯកសារដូចតទៅ:

ក- ពាក្យសុំមានការបំពេញពេញលេញមួយ មានទម្រង់ដូចដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយត្រូវចុះហត្ថលេខាដោយតំណាងពេញសិទ្ធិម្នាក់របស់អ្នកដាក់ពាក្យសុំនោះ ភ្ជាប់ជាមួយលិខិតប្រគល់សិទ្ធិដែលមានសុពលភាព។

ខ- លិខិតមួយច្បាប់រៀបរាប់អំពីគោលបំណងរបស់អ្នកដាក់ពាក្យសុំ ដើម្បីវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមជាមួយនិងការរៀបរាប់សង្ខេបអំពីអ្នកវិនិយោគ គំរោងវិនិយោគ កម្មវត្ថុរបស់អ្នកវិនិយោគ និងសំណើផ្សេង ៗ ទៀតទាក់ទងនឹងគំរោងវិនិយោគនោះ ដែលបានធ្វើឡើងចំពោះក្រុម ប្រឹក្សាអភិវឌ្ឍន៏កម្ពុជា។

គ- ឯកសារពាក់ព័ន្ធដល់ការបង្កើតសហគ្រាសវិនិយោគនោះ ដូចជាអនុសាធារណៈ និងលក្ខន្តិកៈរបស់សហគ្រាសស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ឃ- ការសិក្សាអំពីសមិទ្ធិលទ្ធភាពលំអិតទាំងខាងសេដ្ឋកិច្ច ទាំងខាងបច្ចេកទេសនៃការវិនិយោគរបស់សហគ្រាស រួមទាំងការសង្ខេបអំពីបច្ចេកវិទ្យាផលិតរបស់សហគ្រាសវិនិយោគនោះផង។

ង- ពត៌មានផ្សេងៗទៀតទាក់ទងទៅនឹងការវិនិយោគដែលដាក់ស្នើនោះ តាមការតម្រូវជាយថាហេតុរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា។

ច- សេចក្តីលំអិតអំពីលក្ខណសម្បត្តិទាំងឡាយរបស់អ្នកដាក់ពាក្យសុំ រួមមានដូចតទៅ :

១- សមត្ថភាពបច្ចេកទេស

២- សមត្ថភាពម៉ាឃីតទីង (Marketing)

៣- ធនធានមនុស្ស និងសមត្ថភាពជំនាញគ្រប់គ្រង.

៤- សមត្ថភាពហិរញ្ញវត្ថុ។

៦.២- ថ្លៃនៃពាក្យសុំៈ ក្រោយពីបានពិនិត្យឃើញថា អ្នកវិនិយោគបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ដូចមានចែងក្នុងចំណុច ៦.១ រួចហើយ ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំដល់អ្នកវិនិយោគ ក្នុងរយៈពេលមិនលើសពីម្ភៃបួនម៉ោង (២៤ម៉ោង) ហើយអ្នកវិនិយោគ ត្រូវបង់ថ្លៃដាក់ពាក្យសុំដូចតទៅ:

ក) បើគំរោងវិនិយោគមានតំលៃតិចជា ឬស្មើ ១,000,000 USD:

- ត្រូវបង់ ១00 USD (មួយរយ) នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ៥00 USD (ប្រាំរយ) នៅពេលបានទទួលគោលការណ៏អនុញ្ញាតអោយវិនិយោគ។

ខ) បើគំរោងវិនិយោគមានតំលៃច្រើនជាង ១,000,000 USD:

- ត្រូវបង់ ២00 USD (ពីររយ) នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ១.000 USD (មួយពាន់) នៅពេលបានទទួលគោលការណ៏អនុញ្ញាតអោយវិនិយោគ។

ថ្លៃនៃពាក្យសុំទាំងនេះ ត្រូវចូលថវិការដ្ឋ។

៦.៣- ការសិក្សាអំពីសមិទ្ធិលទ្ធភាពៈ ការសិក្សាអំពីសមិទ្ធិលទ្ធភាព ត្រូវលើកឡើងនូវចំណុចសំខាន់ៗ មួយចំនួនដូចតទៅ :

ក- ទីផ្សារសំរាប់លក់ផលិតផលរបស់សហគ្រាសវិនិយោគ។

ខ- ការប៉ាន់ស្មាននៃតម្រូវការបច្ចេកទេស កំណត់ថ្លៃ និងការប្រកួតប្រជែងផលិតផលរបស់សហគ្រាស វិនិយោគ នោះ។

គ- បច្ចេកទេសផលិតកម្ម រួមទាំងបរិមាណនៃការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ឬក្រៅស្រុក។

ឃ- សមាភាគនាំចូល និងនាំចេញ។

ង- សមាភាគនៃការជួលនិយោជិតសញ្ជាតិខ្មែរ និងបរទេស។

ច- ការវិភាគហិរញ្ញវត្ថុ និងបច្ចេកទេសលើគំរោងវិនិយោគរួមមាន ថ្លៃដើមផលិតកម្ម និងការកំណត់ថ្លៃលក់រាយ ផង។

ឆ- ចំណូលរូបិយប័ណ្ណក្នុងស្រុក និងបរទេស និងលទ្ធភាពបំពេញសេចក្តីត្រូវការនៃការប្តូររូបិយប័ណ្ណ បរទេស។

ជ- ការសិក្សាអំពីហេតុប៉ះពាល់ដល់បរិស្ថានរួមមាន ផែនការលំអិតសំរាប់ចាត់ការ និង ការយកទៅចោលនូវសំណល់ទាំងឡាយ។

ឈ- គំរោងបណ្តុះបណ្តាលធនធានមនុស្ស។

៦.៤- ការអោយផ្តល់ពតិមានបន្ថែមៈ នៅមុនពេលអនុញ្ញាតអោយវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចស្នើសុំពតិមានបន្ថែមពីអ្នកវិនិយោគក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) នៃថ្ងៃធ្វើការយ៉ាងយូរ។ អ្នកវិនិយោគត្រូវផ្តល់ពតិមានជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាវិញ ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតស្នើសុំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៦.៥- ពាក្យសុំដែលបំពេញបែបបទបានពេញលេញៈ ពាក្យសុំមួយត្រូវបានចាត់ទុកថា បានបំពេញបែបបទពេញលេញ និង គ្រប់-គ្រាន់ លុះត្រាណាឯកសារតំរូវទាំងអស់ត្រូវបានដាក់ជូន និងរាល់ពតិមានដែលបានសុំ ត្រូវបានផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានគ្រប់គ្រាន់ហើយ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរនាមករណ៍ ឬអាសយដ្ឋាន ឬទាំងពីរនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) នៃថ្ងៃធ្វើការក្រោយការផ្លាស់ប្តូរនេះ។ ការមិនបានដាក់លិខិតជូនដំណឹងនេះ គឺជាមូលដ្ឋាននៃការផ្អាកការពិនិត្យសំណុំរឿងជាស្វ័យប្រវត្តិ។

មាត្រា៧: ការអនុញ្ញាត និងការដកហូតសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែកដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៧.១- កំឡុងពេលផ្តល់ការអនុញ្ញាតៈ

ក- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួន ចំពោះការផ្តល់ការអនុញ្ញាត ឬការបដិសេធពាក្យសុំ ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំថ្ងៃ (៤៥ថ្ងៃ) នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានទទួលពាក្យសុំ ដែលបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ដូចមានគំនូសបំព្រួញនៃចរាចរឯកសារភ្ជាប់នៅផ្នែកខាងក្រោយនៃអនុក្រឹត្យនេះ។

ខ- សហគ្រាសវិនិយោគត្រូវតំកល់ប្រាក់នៅគណនីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅធនាគារជាតិនៃកម្ពុជា តាមល័ក្ខខ័ណ្ឌ ដូចខាងក្រោមៈ

- ២% នៃទុនវិនិយោគសរុបដែលតិចជាង ឬស្មើ ១.000.000 USD
- ១,៩% នៃទុនវិនិយោគសរុបដែលច្រើនជាង ១.000.000 USD និងតិចជាងឬស្មើ ១0.000.000 USD
- ១,៨% នៃទុនវិនិយោគសរុបដែលច្រើនជាង ១0.000.000 USD និងតិចជាង ឬស្មើ ២0.000.000 USD
- ១,៧% នៃទុនវិនិយោគសរុបដែលច្រើនជាង ២0.000.000 USD និងតិចជាងឬស្មើ ៣0.000.000 USD
- ១,៦% នៃទុនវិនិយោគសរុបដែលច្រើនជាង ៣0.000.000 USD និងតិចជាង ឬស្មើ ៤0.000.000 USD
- ១.៥% នៃទុនវិនិយោគសរុបដែលលើពី ៤0.000.000 USD ឡើងទៅ។

ប្រាក់តំកល់នេះ នឹងបង្វិលសងវិញ នៅពេលដែលសហគ្រាសវិនិយោគអនុវត្តគំរោងបាន ៣0%។

៧.២- ការកែតំរូវពាក្យសុំៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចតំរូវអោយអ្នកដាក់ពាក្យសុំកែតំរូវពាក្យសុំ និងឯកសារណាមួយដែលទាក់ទងទៅនឹងពាក្យសុំ ហើយអ្នកដាក់ពាក្យសុំត្រូវដាក់ជូនសារជាថ្មីនូវពាក្យសុំនោះ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

បន្ទាប់ពីធ្វើការកែតំរូវរួចមកក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) នៃថ្ងៃធ្វើការ។ អ្នកដាក់ពាក្យសុំដែលខកខានពុំបានកែតំរូវតាមដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតំរូវនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងមិនពិនិត្យលើពាក្យសុំនោះឡើយ។

៧.៣- ការអនុញ្ញាត ឬការបដិសេធៈ ការយល់ព្រមអោយវិនិយោគត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា តាមរយៈការចេញអាជ្ញាប័ណ្ណវិនិយោគអោយដល់អ្នកដាក់ពាក្យសុំនោះ។ ការបដិសេធពាក្យសុំ ក៏ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ។

៧.៤- ការដកហូតមកវិញនូវសិទ្ធិ និងផលប្រយោជន៍ និងការរឹបអូសប្រាក់តំកល់ៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានអំណាចដក-ហូតមកវិញនូវសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែកព្រមទាំងរឹបអូស ប្រាក់តំកល់ក្នុងករណីដូចតទៅៈ

ក- គំរោងវិនិយោគនោះ មិនត្រូវបានអនុវត្តស្របទៅតាមតារាងពេលវេលា ដែលបានបញ្ជាក់ក្នុងពាក្យសុំ និងប្រសិនបើពុំបានចាប់ផ្តើមធ្វើដំណើរការអនុវត្តន៍គំរោងវិនិយោគក្នុងរយៈពេល៦ខែ (ប្រាំមួយខែ) បន្ទាប់ពីការចេញអោយនូវអាជ្ញាប័ណ្ណវិនិយោគរួចមក។

ខ- ដើមទុនបង្ហាញចំនួនម្ភៃប្រាំភាគរយ (២៥%) នៃដើមទុនចុះបញ្ជី ដែលបានប្រកាសក្នុងពាក្យសុំទៅក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា ឬទំនិញជាទុនដែលមានតំលៃសមមូល មិនត្រូវបានតំកល់ក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) គិតចាប់ពីថ្ងៃដែលបានអនុញ្ញាតមក។

គ- ដើមទុនវិនិយោគសរុបដែលមិនទាន់បានប្រើប្រាស់គ្រប់ក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) បន្ទាប់ពីថ្ងៃបង្កើតសហគ្រាសវិនិយោគនោះមក។

ឃ- ប្រាក់តំកល់ដែលមានចែងក្នុង ៧.១.ខ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ ដោយស្វ័យប្រវត្តិ បើសហគ្រាសវិនិយោគ មិនបានអនុវត្តគំរោងក្នុងរយៈពេល ០៦ខែ (ប្រាំមួយខែ) បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណវិនិយោគ។

ង- សហគ្រាសវិនិយោគណាមិនបានជូនដំណឹងអំពីការផ្លាស់ប្តូរនាមករណ៍ ឬអាសយដ្ឋានដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេលដប់ថ្ងៃ (១០ថ្ងៃ) មុនការផ្លាស់ប្តូរ។

ច- សហគ្រាសប្តូរមុខសញ្ញាផលិតកម្ម អាជីវកម្ម ដោយមិនបានសុំការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ឆ- សហគ្រាសរំលាយបញ្ចូលជាមួយសហគ្រាសដទៃទៀត ឬផ្ទេរកម្មសិទ្ធិ។

ជ- យោងតាមសំណើពីស្ថាប័នមានសមត្ថកិច្ចលើមូលហេតុមានការរំលោភធ្ងន់ធ្ងរលើច្បាប់ជាធរមាន។

៧.៥- សេចក្តីជូនដំណឹងអំពីការដកហូតសិទ្ធិ និងផលប្រយោជន៍ៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវជូនដំណឹងដល់អ្នកវិនិយោគ ជាលាយលក្ខណ៍អក្សរ នូវសេចក្តីសំរេចរបស់ខ្លួន ចំពោះការដកហូតមកវិញនូវសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែក។

៧.៦- វិធាននៃការដកហូតនូវសិទ្ធិ និងផលប្រយោជន៍ៈ មុនធ្វើការដកហូតមកវិញនូវសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែក ក្រោយពេលធ្វើសេចក្តីជូនដំណឹងដល់សហគ្រាសរួចហើយ ហើយសហគ្រាសមិនបានឆ្លើយតបទៅក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជាវិញ អោយបានទាន់ពេលវេលាកំណត់ ៣០ ថ្ងៃ (សាមសិបថ្ងៃ) នោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តតាមវិធានដូចតទៅ :

- ធ្វើលិខិតរំលឹកដល់សហគ្រាសម្តងទៀត (១៥ថ្ងៃ)
- ធ្វើលិខិតព្រមានដល់សហគ្រាសម្តងទៀត (១៥ថ្ងៃ)
- ធ្វើការពិន័យដោយព្យួរសិទ្ធិ និងផលប្រយោជន៍ ក្នុងរយៈពេល ៦០ថ្ងៃ

- ធ្វើការដកហូតសិទ្ធិ និងផលប្រយោជន៍ជាស្ថាពរ ។

៧.៧- សិទ្ធិតវ៉ាៈ ក្រោយពេលបានទទួលលិខិតជូនដំណឹងអំពីការដកហូតសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែកពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហគ្រាសវិនិយោគអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ២៥ថ្ងៃ ( ម្ភៃប្រាំថ្ងៃ) ចាប់ពីថ្ងៃជូនដំណឹងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## ជំពូក ៣ ការផ្ទេរភាគហ៊ុន

### មាត្រា៨ៈ ការដាក់កំហិតលើការផ្ទេរ

៨.១- បែបបទនៃការសុំផ្ទេរភាគហ៊ុនៈ ពាក្យស្នើផ្ទេរភាគហ៊ុនទីមួយៗ ត្រូវរៀបរាប់អោយបានច្បាស់លាស់អំពីអត្តសញ្ញាណ និងសញ្ជាតិរបស់ភាគីនីមួយៗ ដែលប្រកបអាជីវកម្មក្នុងសហគ្រាសវិនិយោគនោះ ។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំ មិនមែនជារូបវន្តបុគ្គល ពាក្យសុំត្រូវបង្ហាញអោយបានច្បាស់លាស់ នូវចរនាសម្ព័ន្ធកម្មសិទ្ធិរបស់អ្នកដាក់ស្នើសុំដោយលំអិតគ្រប់-គ្រាន់ ដើម្បីអោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានលទ្ធភាពកំណត់នូវអត្តសញ្ញាណនៃម្ចាស់ភាគហ៊ុន ឬភាគីផ្សេងៗទៀតដែលពាក់ព័ន្ធ ។ ពាក្យស្នើផ្ទេរភាគហ៊ុន ត្រូវបញ្ជាក់នូវកម្មសិទ្ធិ ដែលពាក់ព័ន្ធទៅនឹងភាគីនីមួយៗ របស់សហគ្រាសវិនិយោគនោះ ។

៨.២- ការផ្ទេរភាគហ៊ុនៈ អ្នកវិនិយោគនីមួយៗ មានសិទ្ធិផ្ទេរភាគហ៊ុនដែលមាននៅក្នុងសហគ្រាស វិនិយោគរបស់ខ្លួនទៅអោយអ្នកវិនិយោគផ្សេងៗទៀតរបស់សហគ្រាសវិនិយោគនោះបាន ។ ប្រសិនបើ អ្នករួមភាគហ៊ុននោះពុំចង់ទិញភាគហ៊ុនទាំងនេះទេ អ្នកវិនិយោគដែលធ្វើការផ្ទេរនោះ មានសិទ្ធិផ្ទេរភាគហ៊ុនរបស់ខ្លួនទៅអោយតតិយជនដទៃទៀតបាន ។ អ្នកវិនិយោគដែលធ្វើការផ្ទេរនោះ ត្រូវទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាយ៉ាងតិចបំផុត ៣០ថ្ងៃ ( សាមសិបថ្ងៃ) មុនការផ្ទេរភាគហ៊ុននោះ ។

៨.៣- ព្រំដែននៃការផ្ទេរភាគហ៊ុនៈ សហគ្រាសវិនិយោគដែលជានីតិបុគ្គលសញ្ជាតិបរទេស ពុំមានសិទ្ធិធ្វើជាកម្មសិទ្ធិករនៃដីធ្លី ។ សមាជិកវិនិយោគទាំងឡាយនៅក្នុងនីតិបុគ្គលសញ្ជាតិខ្មែរ ដែលជាកម្មសិទ្ធិករ នៃដីធ្លីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានហាមឃាត់ផងដែរ ចំពោះការផ្ទេរភាគហ៊ុនរបស់ខ្លួនដែលនៅក្នុងនីតិបុគ្គលសញ្ជាតិខ្មែរនោះ ប្រសិនបើឥទ្ធិពលនៃការផ្ទេរនោះ បណ្តាលអោយសហគ្រាសវិនិយោគនោះ ក្លាយទៅជានីតិបុគ្គលសញ្ជាតិបរទេស ។ រូបវន្តបុគ្គលនិងនីតិបុគ្គលសញ្ជាតិខ្មែរ ដែលជាកម្មសិទ្ធិករនៃដីធ្លីស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានហាមឃាត់ផងដែរចំពោះការចុះបញ្ជីផ្ទេរភាគហ៊ុនណាមួយ ដែលបណ្តាលអោយសហគ្រាសវិនិយោគនោះ ក្លាយទៅជានីតិបុគ្គល សញ្ជាតិបរទេស ។

## ជំពូក ៤

## ភាគ ១ រូបភាពវិនិយោគ

### មាត្រា៩ៈ រូបភាពវិនិយោគដែលត្រូវបានអនុញ្ញាត

រូបភាពវិនិយោគដែលត្រូវបានអនុញ្ញាតរួមមានៈ

- ប្រភពដើមទុនក្នុងស្រុក ១០០% ( មួយរយភាគរយ).
- ប្រភពដើមទុនបរទេស ១០០% ( មួយរយភាគរយ).

- សហគ្រាសសម្ព័ន្ធអាជីវកម្ម (Joint Venture).
- សាងសង់-អាជីវកម្ម-ផ្ទេរ (B.O.T).
- កិច្ចសន្យាសហប្រតិបត្តិការធុរកិច្ច (B.C.C).
- រូបភាពផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់។

## ភាគ ២ សហគ្រាសសម្ព័ន្ធអាជីវកម្ម (Joint Venture)

### មាត្រា១០: ការបង្កើតសហគ្រាសសម្ព័ន្ធអាជីវកម្ម

សហគ្រាសសម្ព័ន្ធអាជីវកម្ម ត្រូវបានបង្កើតឡើងលើមូលដ្ឋានកិច្ចសន្យាអាជីវកម្មរួម លើគម្រោងមួយដ៏ជាក់លាក់រវាងសហគ្រាសវិនិយោគនៃសញ្ជាតិណាមួយ ឬរវាងរដ្ឋាភិបាល និងសហគ្រាសវិនិយោគណាមួយ។ ដៃគូវិនិយោគនៃសហគ្រាសសម្ព័ន្ធអាជីវកម្មអាចមានសិទ្ធិដាក់ភាគហ៊ុនដោយគ្មានការកំណត់ ក៏ប៉ុន្តែ ការចូលរួមបរទេសមិនត្រូវអោយលើសពី ៤៩% (សែសិបប្រាំបួនភាគរយ) ក្នុងករណីសហគ្រាស វិនិយោគនោះមានបំណងធ្វើជាកម្មសិទ្ធិករដីធ្លី។

### មាត្រា១១: ដើមទុនរបស់សហគ្រាសសម្ព័ន្ធអាជីវកម្ម

១១.១- ដើមទុនជាទ្រព្យសម្បត្តិ: តម្លៃនៃទ្រព្យសម្បត្តិណាមួយ ដែលផ្តល់ទៅអោយសហគ្រាសសម្ព័ន្ធអាជីវកម្ម ត្រូវគិតលើមូលដ្ឋាននៃតំលៃនៅលើទីផ្សារនៃទ្រព្យសម្បត្តិនោះ។ ប្រសិនបើក្រុមអភិវឌ្ឍន៍កម្ពុជាយល់ឃើញថា តម្លៃនៃទ្រព្យសម្បត្តិរបស់ភាគីណាមួយខ្ពស់ជាងតំលៃប៉ាន់ស្មាននៅលើទីផ្សារ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិប្រើប្រាស់តម្លៃប៉ាន់ស្មាននៅលើទីផ្សារនេះ ជាតម្លៃនៃដើមទុនដាក់ចូល ក្នុងសហគ្រាសសម្ព័ន្ធអាជីវកម្ម សំរាប់វាយតម្លៃលើពាក្យសុំ។

១១.២- ទ្រព្យសម្បត្តិ: រោងចក្រ គ្រឿងម៉ាស៊ីន ឬគ្រឿងសម្ភារៈបរិក្ខារដែលអ្នកវិនិយោគមានបំណង ផ្តល់ទៅអោយសហគ្រាសសម្ព័ន្ធអាជីវកម្ម ឬដែលសហគ្រាសសម្ព័ន្ធអាជីវកម្មដាក់ស្នើទិញ គឺត្រូវធានាសុវត្ថិភាពរបស់ពលករក្រោមការទទួលខុសត្រូវរបស់អ្នកវិនិយោគចំពោះមុខច្បាប់។

១១.៣- ដីធ្លី: អ្នកវិនិយោគសញ្ជាតិខ្មែរ អាចផ្តល់ដីធ្លីធ្វើជាភាគហ៊ុនរបស់សហគ្រាសសម្ព័ន្ធអាជីវកម្មបាន។ ការកំណត់តំលៃដីធ្លីនេះត្រូវមានការព្រមព្រៀងគ្នាដោយភាគីទាំងអស់របស់សហគ្រាសសម្ព័ន្ធ អាជីវកម្មនោះ។

## ភាគ ៣ រូបភាពនៃសហគ្រាសផ្សេងៗទៀត

### មាត្រា១២: រូបភាពកិច្ចសន្យា

ក) រូបភាពកិច្ចសន្យាសហប្រតិបត្តិការធុរកិច្ច (BCC): គឺជាកិច្ចសន្យារវាងអ្នកវិនិយោគនៅកម្ពុជា និងនីតិបុគ្គលសាធារណៈណាមួយ ដើម្បីអនុវត្តសកម្មភាពផលិតកម្ម ឬអាជីវកម្មនៅកម្ពុជា ហើយធ្វើការបែងចែកលទ្ធផលដែលទទួលបាន ដោយមិនបង្កើតនីតិបុគ្គលមួយថ្មីផ្សេងទៀតឡើយ។

កិច្ចសន្យាពាណិជ្ជកម្ម ឬសេដ្ឋកិច្ចដែលមានលក្ខណៈជាការផ្លាស់ប្តូរទំនិញ មិនមែនជាកិច្ចសន្យាសហប្រតិបត្តិការធុរកិច្ច (BCC) ដូចមានពោលខាងលើនេះទេ។

ខ) រូបភាពកិច្ចសន្យាសាងសង់-អាជីវកម្ម-ផ្ទេរ (BOT) រូបភាពវិនិយោគនេះ មានចែងលំអិតដោយឡែកក្នុងអនុក្រឹត្យ ស្តីពីសាងសង់-អាជីវកម្ម-ផ្ទេរ។

## ជំពូក ៥ វូបិយប័ណ្ណបរទេស

### មាត្រា១៣: គណនីធនាគារ

១៣.១- ការបើកគណនីធនាគារ: នៅពេលទទួលបានអាជ្ញាប័ណ្ណវិនិយោគ សហគ្រាសវិនិយោគត្រូវបើក គណនីធនាគារមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅធនាគារដែលត្រូវបានទទួលស្គាល់ដោយធនាគារជាតិកម្ពុជា។

១៣.២- ការទូទាត់: អ្នកវិនិយោគត្រូវធ្វើគ្រប់ការទូទាត់ទាំងអស់ ដែលពាក់ព័ន្ធទៅនឹងសហគ្រាសវិនិយោគនោះ តាមរយៈគណនីធនាគារដែលបានបើកស្របតាមមាត្រា ១៣ នេះ។

### មាត្រា១៤: ការខ្ចីបុល-សមាភាគបំណុលដើមទុន

សហគ្រាសវិនិយោគ មិនត្រូវបានអនុញ្ញាតអោយខ្ចីនូវចំនួនទឹកប្រាក់សរុបពីតតីយជន ឬធនាគារលើសពី ចំនួនបីដងនៃមូលធនផ្ទាល់ (Equity) របស់សហគ្រាសវិនិយោគនោះបានឡើយ លើកលែងតែគំរោង អាទិភាពដែលរាជរដ្ឋាភិបាលបានកំណត់។

### មាត្រា១៥: ការបញ្ជូនមូលនិធិចេញទៅបរទេសវិញ

ការបញ្ជូលមូលនិធិចេញទៅបរទេសវិញ ត្រូវអនុលោមទៅតាមព្រះរាជក្រមស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់ លេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ព្រមទាំងបទបញ្ញត្តិទាំងឡាយ ដែលបានកំណត់ និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា។ ការបញ្ជូនចេញនេះ រួមមាន :

១. ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើម ទាំងការនូវប្រាក់ចងការ។

២. ការទូទាត់ចំណាយសួយសារ និងថ្លៃសេវាគ្រប់គ្រង។

៣. ការផ្ទេរប្រាក់ចំណេញ ក្រោយពីបានទូទាត់រាល់កាតព្វកិច្ចហិរញ្ញវត្ថុ និងបានទូទាត់រាល់ពន្ធអាករ និងសោហ៊ុយដែលជាប់ពាក់-ព័ន្ធរួចហើយ។

៤. ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេស ស្របតាមផែនការរំលោះរបស់ក្រុមហ៊ុន។

៥. ប្រាក់សន្សំសំចៃសមស្របសល់ពីការចំណាយប្រាក់បៀវត្ស។

## ជំពូក ៦ កម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី

### មាត្រា១៦: កម្មសិទ្ធិ

១៦.១- កម្មសិទ្ធិ: កម្មសិទ្ធិដីធ្លីសំរាប់បំរើអោយគោលដៅនៃសកម្មភាពវិនិយោគ ដែលត្រូវផ្ដល់ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល សញ្ជាតិខ្មែរ ត្រូវអនុលោមតាម ច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១០០ ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២។

១៦.២- ការចុះបញ្ជីកម្មសិទ្ធិ: ក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លី អ្នកវិនិយោគត្រូវទៅបំពេញបែបបទនៅអង្គភាពសុរិយោដី ក្នុងមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅ។

១៦.៣- កំរិតលើកម្មសិទ្ធិ: អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រូបវន្តបុគ្គល និង នីតិបុគ្គលសញ្ជាតិបរទេស មិនអាចធ្វើជាកម្មសិទ្ធិករនៃដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។

មាត្រា១៧: ការប្រើប្រាស់ដីធ្លី

១៧.១- ករណីអ្នកវិនិយោគសញ្ជាតិខ្មែរ: ក្រៅពីកម្មសិទ្ធិ អ្នកវិនិយោគសញ្ជាតិខ្មែរមានសិទ្ធិប្រើប្រាស់ដីធ្លី តាមរូបភាពផ្សេងៗ ដែលមានជាធរមានដូចជា: សម្បទាន ការជួល ការខ្ចី ការផ្ទេរ អំណោយ ជាដើម ។ ល ។

១៧.២- ករណីអ្នកវិនិយោគសញ្ជាតិបរទេស : អ្នកវិនិយោគសញ្ជាតិបរទេសអាចប្រើប្រាស់ដីធ្លី តាមរយៈការជួលសំរាប់រយៈពេលវែងរហូតដល់ ៧០ឆ្នាំ ហើយអាចស្នើសុំជួលបន្ត។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មសិទ្ធិទាំងឡាយនៅលើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

១៧.៣- ការជួលដីធ្លី: រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិបរទេស ត្រូវបានអនុញ្ញាតអោយជួលដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន អោយតែកិច្ចសន្យាជួលនេះ ធ្វើតាមរូបមន្តនៃលិខិតយថាភូត និងមានបញ្ជាក់ពីល័ក្ខខ័ណ្ឌនៃការជួលការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ ចំពោះថ្លៃឈ្នួលនៅលើទីផ្សារមួយ និងមានការកំណត់រយៈពេលច្បាស់លាស់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលការអនុញ្ញាតអោយជួលដីធ្លីពីរដ្ឋ អាចធ្វើការជួលបន្តបន្ទាប់ទៅរូបវន្តបុគ្គល និងនីតិបុគ្គលដទៃទៀតតាមកិច្ចសន្យាជួលបន្ត ដោយមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ច និងបន្ទាប់ពីមានការអនុវត្តកិច្ចសន្យាជួលពីរដ្ឋអស់រយៈពេលយ៉ាងតិច ៣ឆ្នាំ ( បីឆ្នាំ) លើកលែងតែករណីពិសេសជាក់ស្តែង ។

## ជំពូក ៧ ពន្ធគយ និងពន្ធអាករ

មាត្រា១៨: គោលការណ៍

១៨.១- ការទទួលខុសត្រូវចំពោះពន្ធអាករ : គ្រប់សហគ្រាសវិនិយោគត្រូវជាប់ពន្ធ និងត្រូវប្រតិបត្តិ តាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីហិរញ្ញវត្ថុ និង ច្បាប់ស្តីពីសារពើពន្ធ។ អត្រាពន្ធលើប្រាក់ចំណេញ សំរាប់ការរុករកការធ្វើអាជីវកម្ម ឬ ការកែច្នៃដំបូងនូវធនធានធម្មជាតិមានជាអាទិ៍ ឈើ ប្រេងកាត ឧស្ម័នធម្មជាតិ រ៉ែ មាស និងត្បូងថ្មមានតម្លៃ ត្រូវកំណត់តាមកថាខ័ណ្ឌ២ មាត្រា២០ នៃច្បាប់ស្តីពីសារពើពន្ធ។ សហគ្រាសវិនិយោគអាចទទួលបាននូវសម្បទានខាងពន្ធអាករ ដូចដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី ៣ ។

១៨.២- ការដាក់កំរិតព្រំដែន: ការលើកលែងទាំងស្រុង ឬមួយផ្នែកអំពីពន្ធអាករ និងពន្ធគយដែលក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់អោយ ត្រូវអនុវត្តចំពោះតែពន្ធលើប្រាក់ចំណេញ ពន្ធគយ និងពន្ធអាករ មួយចំនួនលើទំនិញនាំចូល ដូចមានចែងនៅក្នុងអនុក្រឹត្យនេះតែប៉ុណ្ណោះ ។ ការលើកលែងនេះ ពុំរាប់បញ្ចូលករណីដូចខាងក្រោមទេ:

- ក- បំណុលរបស់និយោជិតនៃសហគ្រាសវិនិយោគ ឬកាតព្វកិច្ច និងបំណុលរបស់សហគ្រាសវិនិយោគ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ។
- ខ- បំណុលអាករលើផលរបរ ដែលនឹងជំនួសដោយអាករលើតំលៃបន្ថែម អាករពិសេសលើទំនិញ និង សេវាមួយចំនួនក្រៅពីអាករដែលបានបង់នៅពេលនាំចូល ឬពន្ធអាករដទៃទៀត ក្រៅពីពន្ធលើប្រាក់ចំណេញ និងពន្ធគយ ដូចមានចែងក្នុងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

សហគ្រាសវិនិយោគមិនអាចប្រើប្រាស់អត្រាពន្ធ ៩% សំរាប់ពន្ធលើប្រាក់ចំណេញ ឬបទប្បញ្ញត្តិស្តីពីការយោងការខាតបង់ទៅមុខរយៈពេល ៥ឆ្នាំ ( ប្រាំឆ្នាំ) ចំពោះការខាតបង់ដែលកើតមានឡើងមុនថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៧ បានទេ លើកលែងតែការអនុញ្ញាតអោយប្រើនូវអត្រា ឬការយោងការខាតបង់ទៅមុខនេះ មានចែងក្នុងឯកសារយល់ព្រមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

១៨.៣- ឆ្នាំចាប់ផ្តើម និងវិធានសំរាប់ការយោងការខាតបង់ទៅមុខរយៈពេលប្រាំឆ្នាំៈ ការផាត់ចេញនូវ ការខាតបង់តាមបទប្បញ្ញត្តិស្តីពីការយោងការខាតបង់ទៅមុខរយៈពេលប្រាំឆ្នាំក្នុងមាត្រា ១៤.២ នៃ ច្បាប់ស្តីពីវិនិយោគ ត្រូវកំណត់ឡើងតាមវិធានក្នុងមាត្រា១៧ នៃច្បាប់ស្តីពីសារពើពន្ធ។

## មាត្រា១៩: ពន្ធលើប្រាក់ចំណេញ

១៩.១- ឆ្នាំចាប់ផ្តើមអោយរួចពន្ធលើប្រាក់ចំណេញៈ ការលើកលែងការបង់ពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា១៤.២ នៃច្បាប់ស្តីពីវិនិយោគ ត្រូវចាប់ផ្តើមពីឆ្នាំដែលសហគ្រាសវិនិយោគ បានទទួលប្រាក់ចំណេញជាប់ពន្ធលើកទី ១ ដោយពុំគិតពីបទបញ្ញត្តិនៃការយោងការខាតបង់ទៅមុខ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ឬច្បាប់ស្តីពីវិនិយោគឡើយ ប៉ុន្តែបទប្បញ្ញត្តិផ្សេងទៀត នៃពន្ធលើប្រាក់ចំណេញ ត្រូវយកមកប្រើប្រាស់ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ។

១៩.២- ការកំណត់រយៈពេលលើកលែងពន្ធៈ ល័ក្ខខ័ណ្ឌនានានៃម៉ាទ្រីសមេគុណ ត្រូវតែសំរេចអោយបានយ៉ាងយូរនៅចុងឆ្នាំទីពីរ នៃប្រតិបត្តិការពាណិជ្ជកម្មរបស់សហគ្រាសវិនិយោគ ហើយត្រូវរក្សាល័ក្ខខ័ណ្ឌ នានានៃម៉ាទ្រីសមេគុណនេះអោយបាននៅក្នុងរយៈពេលលើកលែងពន្ធ ដែលនៅសល់ទៅមុខទាំងអស់ទៀត។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចកាត់បន្ថយ ឬបន្ថែមរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដែលបានអនុញ្ញាតរួចហើយ តែមិនលើសពីប្រាំបីឆ្នាំ បើសិនជាល័ក្ខខ័ណ្ឌដែលបានយកមកប្រើ ដើម្បីកំណត់មេគុណរបស់គម្រោងវិនិយោគមានការប្រែប្រួល។

១៩.៣- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញសំរាប់សហគ្រាសវិនិយោគ : ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុង មាត្រា៣១ នៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ចំពោះផលរបរដែលសម្រេចបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៧ និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះផលរបរដែលសម្រេចបានក្រោយថ្ងៃទី៣១ ធ្នូ ១៩៩៦ ត្រូវអនុវត្តលើសហគ្រាសវិនិយោគ ដែលបានទទួលការលើកទឹកចិត្តអោយបង់ពន្ធ លើប្រាក់ចំណេញតាមអត្រា ៩% ដូចមានចែងក្នុងមាត្រា១៤.១ នៃច្បាប់ស្តីពីវិនិយោគ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ មិនត្រូវអនុវត្តលើសហគ្រាសវិនិយោគ ដែលត្រូវបានលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា១៤.២ នៃច្បាប់ស្តីពីវិនិយោគ ទេ។

១៩.៤- ការយកប្រាក់ចំណេញទៅវិនិយោគបន្ត : ដូចមានចែងក្នុងមាត្រា១៤.២ នៃច្បាប់ស្តីពីវិនិយោគ ចំពោះសហគ្រាសវិនិយោគដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំនួនប្រាក់ចំណេញជាប់ពន្ធជាវិជ្ជមាននៅក្នុងឆ្នាំជាប់ពន្ធនោះ អាចកាត់បន្ថយបានត្រឹមតែចំនួនប្រាក់ដែលយកមកវិនិយោគចំពោះរោងចក្រ និងគ្រឿងបរិក្ខារ ដែលប្រើប្រាស់សំរាប់បង្កើនសមត្ថភាពផលិតកម្មរបស់ សហគ្រាសវិនិយោគនៅក្នុងឆ្នាំនោះប៉ុណ្ណោះ។ ចំនួនប្រាក់វិនិយោគដែលយកមកកាត់បន្ថយមិនត្រូវអោយលើសពីចំនួនទឹកប្រាក់ចំណេញជាប់ពន្ធមុនការកាត់បន្ថយនេះទេ។ សំរាប់ការរំលោះមូលដ្ឋាន រំលោះនៃទ្រព្យសកម្មដែលបានមកពីការវិនិយោគខាងលើ គឺជាតម្លៃទ្រព្យសកម្មដកចេញនូវចំនួនទឹកប្រាក់នៃការ កាត់បន្ថយពីប្រាក់ចំណេញជាប់ពន្ធនេះ។

១៩.៥- ការបែងចែកប្រាក់ចំណេញៈ ការបែងចែកប្រាក់ចំណេញ គឺជាការបែងចែកនានា ដែលបាន កំណត់ក្នុងកថាខ័ណ្ឌទី៨ មាត្រា ៣ នៃច្បាប់ស្តីពីសារពើពន្ធ។ ការបែងចែកនេះ មិនត្រូវជាប់ពន្ធតាមមាត្រា ២៦ នៃច្បាប់ស្តីពីសារពើពន្ធ ទេ ប៉ុន្តែត្រូវជាប់ពន្ធតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីសារពើពន្ធ។ ពន្ធនេះ គឺជាពន្ធលើប្រាក់ចំណេញត្រូវបង់មុន។

## មាត្រា២០: ពន្ធគយ និងពន្ធអាករនាពេលនាំចូល

២០.១- ការលើកលែងពន្ធគយ និងពន្ធអាករ: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចផ្តល់ការលើកលែងពន្ធគយ និងពន្ធអាករនាពេលនាំចូល តាមកំរិត តាមប្រភេទវិនិយោគ និងតាមប្រភេទទំនិញ ដូចដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី២។

២០.២- ការពង្វាង ឬការលក់ទំនិញជាទុន សម្ភារៈ និងទំនិញផ្សេងៗដែលបានអោយរួចពន្ធគយ និងពន្ធអាករ: សម្ភារៈ ឬទំនិញណាក្រៅអំពីទំនិញជាទុន ដែលបាននាំចូលក្រោមការលើកលែងពន្ធគយ និងពន្ធអាករដែលមិនបានយកមកប្រើប្រាស់ក្នុងគំរោងវិនិយោគ ហើយក្រោយមកទៀតត្រូវបានយកទៅលក់ ឬ បញ្ចេញពីសហគ្រាសតាមរបៀបណាមួយ ត្រូវស្ថិតនៅក្រោមរបបបង់ពន្ធគយ និង ពន្ធអាករជាស្វ័យប្រវត្តិ ព្រមទាំងត្រូវទទួលរងនូវទោសទណ្ឌផ្នែកគយដទៃទៀត។ ទំនិញជាទុនថ្មី និងទំនិញជាទុនណាមួយដែលបានប្រើប្រាស់ក្នុងរយៈពេលតិចជាង ៥ឆ្នាំ (ប្រាំឆ្នាំ) ដែលបាននាំចូលដោយការលើកលែងពន្ធគយ និង ពន្ធអាករ ហើយក្រោយមកទៀតត្រូវបានយកទៅលក់ ឬបញ្ចេញពីសហគ្រាសតាមរបៀបណាមួយ ត្រូវស្ថិតនៅក្រោមរបបបង់ពន្ធគយ និងពន្ធអាករ ជាស្វ័យប្រវត្តិ ព្រមទាំងត្រូវទទួលរងនូវទោសទណ្ឌ ផ្នែកគយដទៃទៀត លើកលែងតែទំនិញជាទុនណាដែលបានរំលោះត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធរួចហើយ។ ទំនិញជាទុនដែលបានយកមកប្រើប្រាស់ក្នុងរយៈពេល ៥ឆ្នាំជាប់គ្នាជាបន្តបន្ទាប់ ឬ ច្រើនជាងនេះ តាំងពីពេលនាំចូលមក ហើយក្រោយមកទៀតត្រូវបានយកទៅលក់ ឬបញ្ចេញពីសហគ្រាសតាមរបៀបណាមួយ ពន្ធគយ និងពន្ធអាករនឹងត្រូវយកមកអនុវត្តលើតំលៃនៅសល់មិនទាន់រំលោះអស់ នៃទំនិញជាទុននេះ ដោយប្រើរបៀបរំលោះតាមវិធីរំលោះស្មើភាគ។

២០.៣ ការរំលាយសហគ្រាស ឬការសើរើរៀបចំឡើងវិញ: ក្នុងរយៈពេលប្រាំឆ្នាំផលិតកម្មដំបូង បើសិនជាសហគ្រាសវិនិយោគបញ្ឈប់ដំណើការ ឬធ្វើការបែងចែក ឬផ្ទេរទ្រព្យសកម្មតាមការរំលាយសហគ្រាស ឬការសើរើរៀបចំឡើងវិញទាំងស្រុងនូវសហគ្រាសវិនិយោគនោះ ការលើកលែងពន្ធគយ និង ពន្ធអាករនៅក្នុងជំពូកនេះ ត្រូវចាត់ទុកជាមោឃៈ ហើយសហគ្រាសវិនិយោគត្រូវបង់អោយគ្រប់ចំនួននូវ ពន្ធគយ និងពន្ធអាករដែលបានលើកលែង។ ក្រោយរយៈពេលប្រាំឆ្នាំផលិតកម្មដំបូង ប្រសិនបើសហគ្រាសវិនិយោគបញ្ឈប់ដំណើរការ ឬធ្វើការបែងចែក ឬផ្ទេរទ្រព្យសកម្មតាមការរំលាយសហគ្រាស ឬការសើរើរៀបចំឡើងវិញទាំងស្រុងនូវសហគ្រាសវិនិយោគនោះ អំពើនេះត្រូវចាត់ទុកថា ជាការពង្វាង ទ្រព្យសកម្មដូចមានចែងក្នុងមាត្រា ២០.២ នៃអនុក្រឹត្យនេះ។

## មាត្រា២១: កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការលើកលែងពន្ធអាករ ឬពន្ធគយ

កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការលើកលែងណាមួយ ចំពោះពន្ធលើប្រាក់ចំណេញ ពន្ធគយ ឬពន្ធអាករ នាពេលនាំចូល គឺជាកាលបរិច្ឆេទនៃការយល់ព្រមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏ប៉ុន្តែមិនអាចមុនកាលបរិច្ឆេទដែលសហគ្រាសវិនិយោគបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ និងនៅទីចាត់ការគយ និង រដ្ឋាករ ទៅតាមនីតិវិធីចុះបញ្ជីដែលនាយកដ្ឋានទាំងនេះបានកំណត់ និងត្រូវបាននាយកដ្ឋានពន្ធដារផ្តល់ អោយ នូវលេខអត្តសញ្ញាណកម្មសារពើពន្ធ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវក្នុងការផ្តល់នូវឯកសារសមស្របទាំងអស់ ជូនដល់នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និងរដ្ឋាករ ដែលក្នុងនោះត្រូវមាន :

ក- ច្បាប់ចម្លងមួយច្បាប់នៃពត៌មានទាំងអស់ ដែលអ្នកវិនិយោគបានផ្តល់អោយនៅក្នុងដំណើរការដាក់ពាក្យសុំ និង កិច្ចព្រមព្រៀងទាំងអស់ដែលបានធ្វើរវាងអ្នកវិនិយោគជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ខ- ឯកសារយល់ព្រមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនោះមានទាំងពត៌មានទាំងអស់ដែលទាក់ទងនឹងចរន្តហិរញ្ញវត្ថុ របស់ការងារវិនិយោគសម្បទានខាងពន្ធ និងបញ្ជីរាយលំអិតអំពីទំនិញទាំងអស់ ដែលបានទទួលការលើកលែងពន្ធគយ និងពន្ធអាករនាពេលនាំចូល ។

ក្នុងរយៈពេលមួយសប្តាហ៍ ក្រោយថ្ងៃបានទទួលពាក្យសុំចុះបញ្ជីដែលបានបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ និងពត៌មានផ្សេង ៗ ទៀតដែលមាត្រានេះតម្រូវ នាយកដ្ឋានពន្ធដារត្រូវផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ សំរាប់សហគ្រាសវិនិយោគជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាអ្នកទទួលខុសត្រូវក្នុងការប្រគល់លេខអត្តសញ្ញាណកម្មសារពើពន្ធ អោយដល់សហគ្រាសវិនិយោគ និងក្នុងការពន្យល់អំពីការតម្រូវផ្សេងៗ ចំពោះការប្រើប្រាស់លេខអត្តសញ្ញាណកម្មសារពើពន្ធ។ មាត្រានេះត្រូវអនុវត្តផងដែរ ចំពោះសហគ្រាសវិនិយោគដែលមានស្រាប់ ។

## មាត្រា២២: ពន្ធអប្បបរមាសម្រាប់សហគ្រាស វិនិយោគ

ពន្ធអប្បបរមាដូចមានចែងក្នុង មាត្រា៣២ នៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ចំពោះផលរបរដែលសំរេចបានមុនថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៧ និង ពន្ធអប្បបរមា ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះផលរបរដែលសំរេចបានក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៦ ត្រូវអនុវត្តលើរាល់សហគ្រាសវិនិយោគ ទោះបីសហគ្រាសនោះ បានទទួលការលើកទឹកចិត្តអោយបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% ដូចមានចែងក្នុងមាត្រា ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ឬបានទទួលការលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ១៤.២ នៃច្បាប់ស្តីពីវិនិយោគ ក៏ដោយ ។

## មាត្រា២៣: កាតព្វកិច្ចរបស់សហគ្រាសវិនិយោគ

២៣.១- ការដាក់លិខិតប្រកាសសារពើពន្ធ: សហគ្រាសទាំងអស់ ដែលបានទទួលការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅក្រោមច្បាប់ស្តីពីវិនិយោគ ទោះបីជាមានការលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ១៤.២ នៃច្បាប់ស្តីពីវិនិយោគក៏ដោយ ត្រូវដាក់ជូននាយកដ្ឋានពន្ធដារនូវលិខិតប្រកាសសារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ សំរាប់ពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស អាករលើផលរបរ ដែលនឹងត្រូវជំនួសដោយអាករលើតម្លៃបន្ថែមអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងពន្ធអាករដទៃទៀត ដោយចាប់ផ្តើមពីពេលដែលសហគ្រាសបានទទួលការយល់ព្រម ។

សហគ្រាសដែលមានស្រាប់មានរយៈពេលកៅសិបថ្ងៃ (៩០ថ្ងៃ) បន្ទាប់ពីការចូលជាធរមាននៃអនុក្រឹត្យនេះ ដើម្បីរបតិបត្តិតាមបញ្ញត្តិទាំងឡាយនៃជំពូកនេះ ហើយដែលផុតរយៈពេលនេះទៅ ទោសទណ្ឌនានាដូចមានចែងក្នុងមាត្រា ២៤ នៃអនុក្រឹត្យ ត្រូវយកមកអនុវត្ត ។

២៣.២- ការផ្តល់ពត៌មានទាក់ទងដល់ការនាំចូលទំនិញជាទុន សម្ភារ: និងទំនិញផ្សេងៗទៀត: ការនាំចូលទំនិញជាទុន សម្ភារ: និងទំនិញផ្សេងៗទៀត ដែលជាចំណែកមួយនៃគំរោងវិនិយោគដែលបានទទួលការយល់ព្រម ត្រូវតែមានការបំពេញបែបបទគយអោយបានសព្វគ្រប់ត្រឹមត្រូវ ។ ក្នុងរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) ក្រោយនាំចូល សហគ្រាសវិនិយោគត្រូវដាក់ជូននាយកដ្ឋានពន្ធដារ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវច្បាប់ចម្លងមានការបញ្ជាក់ត្រឹមត្រូវនៃឯកសារបំពេញបែបបទគយក្នុងនោះមាន ទាំងឯកសារបញ្ជាក់តំលៃទំនិញរបស់ភ្នាក់ងារ ដែលរដ្ឋាភិបាលបានជ្រើសតាំងផង ។

២៣.៣- ការផ្តល់ពត៌មានផ្សេងៗទៀត : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសហគ្រាសវិនិយោគ ត្រូវផ្តល់ជារៀងរាល់ខែ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ ជូននាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និង រដ្ឋាករនូវ:

ក- ចលនាទុនវិនិយោគជាក់ស្តែងរបស់គំរោងវិនិយោគ ដែលបានទទួលការយល់ព្រម ។

ខ- បញ្ជីរាយលំអិត អំពីការនាំចូលជាក់ស្តែង នូវទំនិញដែលបានទទួលការយល់ព្រមសំរាប់គំរោង វិនិយោគ។

គ- បញ្ជីរាយលំអិតអំពីការផ្ញើរទៅបរទេសនូវប្រាក់ចំណេញ ឬការប្រាក់ដែលជាលទ្ធផលនៃសកម្មភាពគំរោងវិនិយោគ។

ឃ- បញ្ជីរាយលំអិតអំពីការទូទាត់អោយដល់ប្រភពក្នុងស្រុកនូវប្រាក់ចំណេញ និង ការប្រាក់ដែលជាលទ្ធផលនៃសកម្មភាពគំរោងវិនិយោគ។

ង- ការប្រែប្រួលណាមួយអំពីអាសយដ្ឋានរបស់តំណាងនៃសហគ្រាសវិនិយោគ ឬ អំពីពត៌មានទាក់ទិនដល់ការដាក់ពាក្យសុំពីដំបូង ដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬការដាក់ពាក្យសុំលេខអត្តសញ្ញាណកម្មសារពើពន្ធ។ ចំពោះពត៌មានទាំងអស់ ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬសហគ្រាសវិនិយោគត្រូវផ្តល់នោះ ត្រូវមានចុះនូវលេខអត្តសញ្ញាណកម្ម សារពើពន្ធដែលនាយកដ្ឋានពន្ធដារបានចេញអោយដើម្បីសំគាល់សហគ្រាស។

មាត្រា២៤: ទោសទណ្ឌ

ក្នុងករណីដែលសហគ្រាសវិនិយោគ មិនបានអនុវត្តកាតព្វកិច្ចនានា ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ សហគ្រាសវិនិយោគត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុង ច្បាប់ស្តីពីហិរញ្ញវត្ថុ និង ច្បាប់ស្តីពីសារពើពន្ធ។ បន្ថែមលើនេះទៀត សហគ្រាសវិនិយោគដែលមិនបានដាក់លិខិតប្រកាស សារពើពន្ធ និងឯកសារបញ្ជាក់ ឬក៏មិនបានផ្តល់ពត៌មានជូននាយកដ្ឋានពន្ធដារ តាមការតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ និងច្បាប់ស្តីពីសារពើពន្ធ ត្រូវទទួលរងការដកហូតការលើកលែងពន្ធអាករ និងពន្ធគយទាំងអស់ ដែលបានផ្តល់អោយនៅក្រោមច្បាប់ស្តីពីវិនិយោគ ហើយត្រូវបង់ជាបន្ទាន់នូវពន្ធអាករ និង ពន្ធគយទាំងអស់ ដែលត្រូវបានលើកលែង ព្រមទាំងប្រាក់ពន្ធលើប្រាក់ចំណេញដែលត្រូវបានកាត់បន្ថយ តាមការអនុវត្តអត្រាពន្ធលើប្រាក់ចំណេញលើកទឹកចិត្ត ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់ស្តីពីវិនិយោគ។

## ជំពូក ៨ ការប្រើប្រាស់កំលាំងពលកម្ម

មាត្រា២៥: ការប្រើប្រាស់កំលាំងពលកម្មសញ្ជាតិបរទេស

ការប្រើប្រាស់កំលាំងពលកម្មសញ្ជាតិបរទេស នៅគ្រប់គ្រឹះស្ថានសហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាម ច្បាប់ស្តីពីការងារ និង ច្បាប់ស្តីពីអន្តោប្រវេសន៍។

មាត្រា២៦: ការប្រើប្រាស់កំលាំងពលកម្មសញ្ជាតិខ្មែរ

២៦.១- ការប្រើប្រាស់កំលាំងពលកម្មសញ្ជាតិខ្មែរ: បើនិយោជិតមានបទពិសោធន៍ និងជំនាញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា សហគ្រាសវិនិយោគត្រូវផ្តល់អាទិភាពក្នុងការប្រើប្រាស់កំលាំងពលកម្មសញ្ជាតិខ្មែរ។

២៦.២- កិច្ចសន្យាជួលកំលាំងពលកម្ម: រាល់កិច្ចសន្យាជួលកំលាំងពលកម្ម ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃច្បាប់ការងារ។

## ជំពូក ៩ ការការពារកម្មសិទ្ធិបញ្ញា (Intellectual Property)

មាត្រា២៧: កម្មសិទ្ធិបញ្ញា

២៧.១- ការរៀបចំបែបបទសុំ: អ្នកវិនិយោគអាចស្នើសុំសំរាប់ការការពារកម្មសិទ្ធិបញ្ញា ដោយរៀបចំ បែបបទដាក់នៅការិយាល័យចុះបញ្ជីកម្មសិទ្ធិបញ្ញានៅក្រសួងមានសមត្ថកិច្ច។

២៧.២- ការអនុវត្តច្បាប់: រាល់បញ្ហាដែលពាក់ព័ន្ធទៅនឹងផ្លាកសញ្ញាពាណិជ្ជកម្ម ប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចម្លង និងស្នាដៃជំនាញនានា ត្រូវអនុវត្តតាមច្បាប់ដែលពាក់ព័ន្ធទៅនឹងច្បាប់កម្មសិទ្ធិបញ្ញា។

# ជំពូក ១០ អវសានបញ្ញត្តិ

មាត្រា២៨:

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

មាត្រា២៩:

អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

# ឧបសម្ព័ន្ធទី ១

ជាចំណែកនៃអនុក្រឹត្យលេខ................................ ចុះថ្ងៃទី ..................

**ភាគ ក បញ្ជីនៃវិស័យសំរាប់វិនិយោគដែលត្រូវបានទទួលការលើកទឹកចិត្ត**

**១. ផលិតកម្មកសិផល**

១.១ ផលិតកម្មស្រូវ ពី ១.០០០ ហត ឡើងទៅ

១.២ ដំណាំរូបិយវត្ថុគ្រប់ប្រភេទ ពី ៥០០ ហត ឡើងទៅ

១.៣ បន្លែពី ៥០ ហត ឡើងទៅ

**២. ផលិតកម្មបសុសត្វ**

២.១ សត្វចតុបាត ពី ១.០០០ ក្បាល ឡើងទៅ

២.២ កសិដ្ឋានផលិតកម្មទឹកដោះ ពី ១០០ ក្បាល ឡើងទៅ

២.៣ បសុបក្សី និងស៊ុត ពី ១០.០០០ ក្បាល ឡើងទៅ

**៣. ជលផល**

៣.១ កសិដ្ឋានភ្ញាស់កូនត្រី ពី ២ ហត ឡើងទៅ

៣.២ កសិដ្ឋានចិញ្ចឹមបង្គារ និងផលិតកម្មជលផលផ្សេងៗ ពី ១០ ហត ឡើងទៅ

**៤. ផលិតកម្ម និងការកែច្នៃម្ហូបអាហារ និងផលិតផលដែលទាក់ទង**

ដើមទុនវិនិយោគសមមូល ៥០០.០០០ USD ឡើងទៅ :

៤.១ ភេសជ្ជៈ

៤.២ ខ្លាញ់ និងប្រេង

៤.៣ គ្រឿងផ្អែម (បង្អែម)

៤.៤ ផលិតផលសាច់

៤.៥ ផលិតផលទឹកដោះ

៤.៦ ផ្លែឈើ និងបន្លែកំប៉ុង

៤.៧ ផលិតផលពីម្សៅមី

៤.៨ ផលិតផលដុតពីឡ (Bakery Products)

៤.៩ ផលិតផលចំណីសត្វ

**៥. ផលិតផលសំរាប់រោងចក្រវាយនភ័ណ្ឌ**

ដើមទុនវិនិយោគសមមូល ១.០០០.០០០ USD ឡើងទៅ :

៥.១ រោងចក្រវេញកប្បាស និងរោងចក្រសរសៃអំបោះ

៥.២ រោងចក្រក្រណាត់ប៉ាក់

៥.៣ រោងចក្រកំរាលព្រំ

៥.៤ តម្បាញផ្សេងៗ

**៦. ការផលិតសំលៀកបំពាក់ និងវាយនភ័ណ្ឌផ្សេងៗទៀត**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ

**៧. ការផលិតគ្រឿងសង្ហារឹម និងគ្រឿងសំរាប់តាំងភ្ជាប់**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ :

៧.១ គ្រឿងសង្ហារឹមសំរាប់ផ្ទះសម្បែង

៧.២ គ្រឿងសង្ហារឹមសំរាប់ការិយាល័យ

៧.៣ ការផលិតរបាំងអាគារ និងគ្រឿងតាំងភ្ជាប់ (Manufacturing of Building Partitions and Fixtures)

**៨. ការផលិតក្រដាស និងផលិតផលរួមសម្ព័ន្ធ**

ដើមទុនវិនិយោគសមមូល ១.000.000 USD ឡើងទៅ :

៨.១ ចំការដើមឈើធ្វើក្រដាស និងរោងចក្រក្រដាស

៨.២ ក្រដាស

៨.៣ រោងចក្រក្រដាសបន្ទះ (Paperboad Mills)

៨.៤ ប្រអប់ធ្វើអំពីក្រដាសបន្ទះ (Paperboad Containers)

**៩. ការផលិតធាតុគីមី និងផលិតផលរួមសម្ព័ន្ធ (Allied Products)**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ :

៩.១ ធាតុគីមីគ្រប់ប្រភេទ រួមទាំងធាតុគីមីកសិកម្ម

៩.២ ជ័រប្លាស្ទិក និងកៅស៊ូសំយោគផ្សេងៗទៀត

៩.៣ ឱសថ

៩.៤ ថ្នាំគីមីសំអាត (Cleaning Products)

៩.៥ ផលិតផលថ្នាំពណ៌ និងផលិតផលរួមសម្ព័ន្ធ (Paints & Allied Products)

**១០. ការផលិតកៅស៊ូ និងជ័រប្លាស្ទិកផ្សេងៗទៀត**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ

**១១. ការផលិតផលិតផលស្បែក និងការផលិតផលិតផលផ្សេងៗទៀត**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ

**១២. ការផលិតផលិតផលធ្វើពីលោហៈគ្រប់ប្រភេទ**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ

**១៣. ការផលិតសំភារៈបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក**

ដើមទុនវិនិយោគសមមូល ៥00.000 USD ឡើងទៅ

**១៤. ការផលិតសំភារៈបរិក្ខារដឹកជញ្ជូន**

១៤.១ យានយន្ត និងគ្រឿងបន្លាស់

១៤.២ យន្តហោះ និងគ្រឿងបន្លាស់

១៤.៣ សំណង់ និងមធ្យោបាយដឹកជញ្ជូនផ្លូវទឹក

១៤.៤ សំភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនផ្លូវដែក

១៤.៥ ទោចក្រយាន និងទោចក្រយានយន្ត

**១៥. ការសាងសង់ស្ពានថ្នល់**

**១៦. អាជីវកម្មរ៉ែ លោហធាតុ-ត្បូងថ្ម-ប្រេង និងឧស្ម័ន**

**១៧. ការផលិតគ្រឿងម៉ាស៊ីន និងសំភារៈបរិក្ខារឧស្សាហកម្ម**

ដើមទុនវិនិយោគ ១.០០០.០០០ USD ឡើងទៅ

**១៨. ការផលិតឧបករណ៍ប្រើប្រាស់**

**១៩. សំណង់សណ្ឋាគារ ចាប់ពីខ្នាតផ្កាយ ៣ ឡើងលើ**

**២០.មន្ទីរពេទ្យពហុព្យាបាលខ្នាតអន្តរជាតិ-អាគារសិក្សាខ្នាតអន្តរជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈ**

**២១. សំណង់ហេដ្ឋារចនាសម្ព័ន្ធបំរើវិស័យវប្បធម៌ និងសិល្បៈ**

**២២. សកម្មភាពផលិតកម្ម-អាជីវកម្មបំរើអោយកិច្ចការពារបរិស្ថាន។**

## ភាគ ខ បញ្ជីនៃវិស័យវិនិយោគ ដែលមិនត្រូវបានទទួលការលើកទឹកចិត្ត

១- សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ

២- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ

៣- ហាងលក់ទំនិញរួចពន្ធគយ (Duty Free Shops)

៤- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល និងកន្លែងធ្វើសរសៃផ្សេងទៀត ដែលស្ថិតនៅក្រៅបរិវេណ សណ្ឋាគារខ្នាតអន្តរជាតិ

៥- មជ្ឈមណ្ឌលពាណិជ្ជកម្ម

៦- សកម្មភាពដែលទាក់ទងនឹងសារពត៌មាន និងប្រព័ន្ធឃោសនា (វិទ្យុ ទូរទស្សន៍ សារពត៌មាន)

៧- លក់រាយ និងលក់ដុំ

៨- សេវាផ្នែកជំនាញ (Professional Services)

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

# ឧបសម្ព័ន្ធទី ២

ជាចំណែកនៃអនុក្រឹត្យលេខ.................................. ចុះថ្ងៃទី ...................

**ការលើកលែងពន្ធគយ និងពន្ធអាករ**

ក/ ប្រភេទវិនិយោគដែលបានទទួលការលើកលែងពន្ធគយ និងពន្ធអាករ :

១- ការវិនិយោគដែលមានទិសដៅសំរាប់បំរើអោយការនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតផល សរុប

២- ការវិនិយោគដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស

៣- ការវិនិយោគនៃឧស្សាហកម្មទេសចរណ៍

៤- ការវិនិយោគនៃឧស្សាហកម្មប្រើប្រាស់កំលាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិឧស្សាហកម្ម

៥- ការវិនិយោគនៃការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល ។

ប៉ុន្តែក្នុងករណីការវិនិយោគក្នុង ៣-៤ និង ៥- ខាងលើ ការលើកលែងពន្ធគយសំរាប់តែក្នុងរយៈពេលនៃ ការរៀបចំកសាងសហគ្រាស រោងចក្រ អាគារ និងការចាប់ដំណើរការអាជីវកម្មផលិតកម្មក្នុងមួយឆ្នាំ ដំបូងតែប៉ុណ្ណោះ ។

ខ/ ប្រភេទទំនិញនាំចូលដែលបានទទួលការលើកលែងពន្ធគយ និងអាករ :

១- សំភារៈសំណង់សំរាប់សហគ្រាសវិនិយោគ

២- គ្រឿងម៉ាស៊ីនប្រើប្រាស់ផ្ទាល់ក្នុងដំណើរការផលិតកម្ម

៣- សំភារៈបរិក្ខារផ្សេងៗទៀត ប្រើប្រាស់ផ្ទាល់ក្នុងសហគ្រាសវិនិយោគ ក្រៅពីសំភារៈបរិក្ខាររដ្ឋបាល សំភារៈបរិក្ខារនៃមធ្យោបាយដឹកជញ្ជូន និងចែកចាយដែលមិនបំរើផ្ទាល់ក្នុងខ្សែចង្វាក់ផលិតកម្ម

៤- គ្រឿងបន្លាស់សំរាប់គ្រឿងម៉ាស៊ីន និងសំភារៈបរិក្ខារនៃចំណុច ២- និង ៣-

៥- វត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសំរេច ប្រើប្រាស់ផ្ទាល់ក្នុងដំណើរការផលិតកម្ម និង

៦- សំភារៈវេចខ្ចប់

គ/ ប្រភេទទំនិញនាំចេញដែលបានទទួលការលើកលែងពន្ធគយ ១០០% :

- ផលិតផលសំរេច

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

# ឧបសម្ព័ន្ធទី ៣

ជាចំណែកនៃអនុក្រឹត្យលេខ......................... ចុះថ្ងៃទី .............................

**សម្បទានពន្ធ** (Tax Concessions)

**របៀបគណនាម៉ាទ្រីស**

ចំពោះ លក្ខណៈវិនិច្ឆ័យ (criteria) នីមួយៗឆ្លើយតបទៅនឹងមាត្រដ្ឋានតំលៃ (value): តំលៃ (value) នោះអាចជា ចំនួនទឹក-ប្រាក់ ចំនួនលេខ ឬចំនួនភាគរយ ។

ចំពោះ តំលៃ (value) នីមួយៗឆ្លើយតបទៅនឹងមេគុណ (coefficient) មេគុណសរុបត្រូវបានប្រើប្រាស់ សំរាប់កំណត់ទីកន្លែងនៅក្នុងមាត្រដ្ឋាននៃរយៈពេលលើកលែងពន្ធ (tax holiday scale) ដើម្បីទទួលបាន ចំនួនឆ្នាំលើកលែងពន្ធដែលឆ្លើយតបទៅនឹងមេគុណនោះ ។

ក៏ប៉ុន្តែ តំលៃដែលយកមកគិតតែងតែពុំឆ្លើយតបត្រូវគ្នាពិតប្រាកដទៅនឹងតំលៃ (value) ទាំងឡាយដែល មាននៅក្នុងមាត្រដ្ឋានឡើយ ។ ក្នុងករណីនេះ ការគណនាត្រូវបានធ្វើតាមវិធី interpolation គឺយកតួលេខណាដែលនៅជិតតំលៃដែលយកមកគិតនោះជាងគេ ។ ប្រសិនបើមេគុណសរុបខិតជិតតួលេខដែលខ្ពស់ ជាងគេនៅក្នុងកូឡោនដេក ហើយតិចជាងពីរភាគរយនៃលេខខ្ពស់ត្រូវយកកូឡោនដេកបន្ទាប់នៃតារាង មកគណនាចំនួនឆ្នាំដែលត្រូវបានលើកលែងពន្ធ ។

**និយមន័យអំពីលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច**

**ទីតាំង :** ដើម្បីជំរុញ និងការលើកទឹកចិត្តដល់តំបន់ចាញ់ប្រៀប ព្រះរាជាណាចក្រកម្ពុជាត្រូវបានចែក ចេញជាបួនតំបន់ដូចតទៅ :

**តំបន់ ១ :** ភ្នំពេញ ខេត្តកណ្តាល ខេត្តសៀមរាប ក្រុងព្រះសីហនុ

**តំបន់ ២ :** ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ

**តំបន់ ៣ :** ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តពោធិសាត់

**តំបន់ ៤ :** ខេត្តបន្ទាយមានជ័យ ខេត្តក្រចេះ ខេត្តកោះកុង ខេត្តមណ្ឌលគីរី ខេត្តព្រះវិហារ ខេត្តរតនគីរី ខេត្តស្ទឹងត្រែង

ខេត្តទាំងឡាយណាដែលស្ថិតនៅក្នុងតំបន់ដែលមានលេខរៀងខ្ពស់ជាងគេ ត្រូវបានចាត់ទុកថាជាតំបន់ចាញ់ប្រៀបជាងតំបន់ទាំងឡាយណាដែលមានលេខរៀងតូចជាង ។

**តំលៃវិនិយោគៈ** ដើមទុននេះបង្ហាញនូវតំលៃនៃការវិនិយោគ (ជាដុល្លារអាមេរិក) ដែលប្រើប្រាស់ទុនជាអចលនៈទ្រព្យ និងចលនទ្រព្យ ដូចជា ការកែលំអដី សំណង់ ចលនទ្រព្យតាំងភ្ជាប់ គ្រឿងម៉ាស៊ីន និង បរិក្ខារ យានយន្ត គ្រឿងសង្ហារឹម និងសំភារៈការិយាល័យ ។

**ចំនួននាក់ចែកនឹងការជួលបុគ្គលិក :** គឺជាចំនួនពលរដ្ឋកម្ពុជា ដែលបានជួលក្នុងផលិតកម្មពេញលេញ ។

**ការនាំចេញ :** លក្ខណៈវិនិច្ឆ័យ ១ចរិតភិច នេះសំដែងជាភាគរយដោយសមាសភាគ ផលិតផលនាំចេញ ចែកនឹងផលិតផលសរុប (ជាចំនួន ឬមាឌ) ។

**តំលៃបន្ថែម** (value added) តំលៃបន្ថែម ត្រូវបានកំណត់យកតំលៃផលិតផលសរុបដកនឹងតំលៃផលិត ផលពាក់កណ្តាលសំរេច ។ ផលិតផលពាក់កណ្តាលសំរេចរួមបញ្ចូលទាំងផលិតផល និងសេវាដែលទិញមកពីក្រៅ ហើយប្រើប្រាស់ដោយសហគ្រាស សំរាប់សកម្មភាពផលិតកម្ម : វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសំរេច ផលិតផលសំរេច សំភារៈផ្គត់ផ្គង់ ទឹកភ្លើង ទូរស័ព្ទ និង ទូរសារ

ការជួល (ដី សំណង់អាគារ និងជួលសំភារៈបរិក្ខារផ្សេងៗ) មធ្យោបាយដឹកជញ្ជូន សេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មកំរៃជើងផ្សារ ថ្លៃឈ្នួលផ្សេងៗ និងសេវាកម្មទិញមកពីក្រៅផ្សេងៗទៀត។

**ការប្រើប្រាស់ធនធានក្នុងស្រុក :** គិតជាភាគរយដោយសមាភាគ តំលៃទិញធនធានក្នុងស្រុកចែកនឹង តំលៃវិនិយោគសរុប។

**ការបណ្តុះបណ្តាល និងអភិវឌ្ឍន៏ធនធានមនុស្ស :** ចំនួនបុគ្គលិកសញ្ជាតិខ្មែរចែកនឹងចំនួនថ្ងៃបណ្តុះ បណ្តាលបុគ្គលិកសញ្ជាតិខ្មែរ។ អ្នកគ្រប់គ្រងត្រូវគិតពីរដង។

**លក្ខណៈវិនិច្ឆ័យសង្គម :**

ការជួលនារីភេទ : ភាគរយនៃកំលាំងពលកម្ម។

ការជួលជនពិការ : ភាគរយនៃកំលាំងពលកម្ម។